# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបំពេញផ្ទៃដីបន្ថែមចំនួន ២៣,៧២ ហិកតា លើអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពី កំណត់ផ្ទៃដីកោះពេជ្រ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពី ការកំណត់ផ្ទៃដីកោះពេជ្រ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានកំណត់បំពេញបន្ថែមផ្ទៃដីចំនួន ២៣,៧២ ហិកតា ( ម្ភៃបីកន្លក់សញ្ញាចិតសិបពីរ ) នៅផ្នែកខាងជើង និងខាងកើតកោះពេជ្រ លើអនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីការកំណត់ផ្ទៃដីកោះពេជ្រ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ផ្ទៃដីចំនួន ២៣,៧២ ហិកតា នេះ ត្រូវបានកំណត់តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ Geocraphical Position System, GPS DATUM : INDIAN- THAILAND 1960 ) រួមមាន ១៨ ចំណុច ដូចខាងក្រោម :

| ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ | ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|---|---|
| 1 | A | 493 855 | 1 277 071 | 10 | J | 494 377 | 1 276 575 |
| 2 | B | 493 887 | 1 277 239 | 11 | K | 494 346 | 1 276 377 |
| 3 | C | 493 975 | 1 277 358 | 12 | L | 494 283 | 1 276 249 |
| 4 | D | 494 085 | 1 277 393 | 13 | M | 494 164 | 1 276 089 |
| 5 | E | 494 195 | 1 277 381 | 14 | N | 493 985 | 1 275 921 |
| 6 | F | 494 289 | 1 277 324 | 15 | O | 493 676 | 1 275 742 |
| 7 | G | 494 355 | 1 277 162 | 16 | P | 493 398 | 1 275 666 |
| 8 | H | 494 370 | 1 276 958 | 17 | Q | 493 347 | 1 275 677 |
| 9 | I | 494 377 | 1 276 780 | 18 | R | 493 300 | 1 275 760 |

**មាត្រា ២ :** ផែនទីបង្ហាញទីតាំងភូមិសាស្ត្រនៃផ្ទៃដីបំពេញបន្ថែម ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៣ :**
- បទដ្ឋានបច្ចេកទេសទាក់ទងនឹងរបបជលសាស្ត្រ ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ត្រូវបានកំណត់ឱ្យធ្វើការពង្រីងច្រាំងទន្លេបាសាក់ផ្នែកខាងកោះនរា ដោយត្រូវចាក់បំពេញ និងកែសម្រួលច្រាំងមានប្រវែងពី 30 m – 50 m ពីមាត់ច្រាំងបច្ចុប្បន្ន ។ ឯនៅខាងផ្នែកទន្លេបាសាក់ធំត្រូវរក្សាទទឹងទន្លេប្រវែង 382 ម៉ែត្រ ( ផ្នែកខាងជើង ) និងរួមតូចដល់ប្រវែង 290 ម៉ែត្រ ( នៅផ្នែកខាងត្បូង ) ។
- ត្រូវកាយផ្ទៃដីដែលដុះ ចាក់បំពេញលើសចំនួន 18,30 ហិកតា ចេញ ដើម្បីរៀបចំច្រាំងកោះពេជ្រឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ។

**មាត្រា ៤ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ